**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ៨៦ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការផ្លាស់ និងតែងតាំង មន្ត្រីការទូតជាន់ខ្ពស់ប្រចាំស្ថានតំណាង នៃព្រះរាជាណាចក្រកម្ពុជានៅបរទេស

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានឃើញអនុក្រឹត្យលេខ ២៣៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញអនុក្រឹត្យលេខ ១០៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស
- បានឃើញអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២០ ស្តីពីការកែប្រែ និងដំឡើងបៀវត្សប្រចាំខែ និងការឧបត្ថម្ភផ្សេងៗសម្រាប់មន្ត្រីរាជការ និងបុគ្គលិកបំពេញភារកិច្ចតាមស្ថានតំណាងកម្ពុជានៅបរទេស
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សម្រេច

**មាត្រា១** : ត្រូវបានផ្លាស់ និងតែងតាំង មន្ត្រីការទូតជាន់ខ្ពស់ ប្រចាំស្ថានតំណាងកម្ពុជានៅបរទេស ដូចមានរាយនាមខាងក្រោម៖

១-ផ្លាស់លោកស្រី **ឡុត គន្ធា** ទីប្រឹក្សា នៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំប្រទេសអូស្ត្រាលី ចូលប្រទេស ដោយចប់អាណត្តិបេសកកម្ម។

-តែងតាំងលោក **លឹម សម្បត្តិ** បច្ចុប្បន្នជំនួយការរដ្ឋមន្ត្រីឋានៈស្មើអគ្គនាយករង ជាទីប្រឹក្សា នៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំប្រទេសអូស្ត្រាលី ជំនួសវិញ។

២-ផ្លាស់លោក **ស្រេង សារ៉ាវុធ** អគ្គទីប្រឹក្សា នៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋប្រជាមានិតចិន ចូលប្រទេស ដោយចប់អាណត្តិបេសកកម្ម។

-តែងតាំងកញ្ញា **ញឹក សុបរមា** បច្ចុប្បន្នប្រធាននាយកដ្ឋានកិច្ចការសហគមន៍នយោបាយ-សន្តិសុខអាស៊ាន ជាអគ្គទីប្រឹក្សា នៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋប្រជាមានិតចិន ជំនួសវិញ។

៣-ផ្លាស់លោក **អ៊ុំ សុភាន** ទីប្រឹក្សា នៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋបារាំង ចូលប្រទេស ដោយចប់អាណត្តិបេសកកម្ម។

-តែងតាំងលោកស្រី **ឡាំ បញ្ញាពរ** បច្ចុប្បន្នប្រធាននាយកដ្ឋានកិច្ចការទូទៅ ជាទីប្រឹក្សា នៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋបារាំង ជំនួសវិញ។

៤-ផ្លាស់លោកស្រី **ឯក ម៉ូលី** ទីប្រឹក្សា នៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំរដ្ឋគូវ៉ែត ចូលប្រទេស ដោយចប់អាណត្តិបេសកកម្ម។

-តែងតាំងលោក **សៀង ម៉ាច់** បច្ចុប្បន្នអនុប្រធាននាយកដ្ឋានពិធីការ ជាទីប្រឹក្សា នៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំរដ្ឋគូវ៉ែត ជំនួសវិញ។

៥-ផ្លាស់លោកស្រី **ឯក ខន្ធវឌ្ឍនី** ទីប្រឹក្សា នៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋកូរ៉េ ចូលប្រទេស ដោយចប់អាណត្តិបេសកកម្ម។

-តែងតាំងលោក **លន់ សារឿន** បច្ចុប្បន្នអនុប្រធាននាយកដ្ឋានអាស៊ីបូព៌ា ជាទីប្រឹក្សា នៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋកូរ៉េ ជំនួសវិញ។

៦-ផ្លាស់លោក **ខែម រុយហ្សុន** ទីប្រឹក្សា នៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសហរដ្ឋអាមេរិក ចូលប្រទេស ដោយចប់អាណត្តិបេសកកម្ម។

-តែងតាំងលោក **អ៊ុំ សុជាតិ** បច្ចុប្បន្នប្រធាននាយកដ្ឋានភាសាបរទេស ជាទីប្រឹក្សា នៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសហរដ្ឋអាមេរិក ជំនួសវិញ។

៧-ផ្លាស់លោក **ឡៅ ថារ៉ាវ៉ាត់** ទីប្រឹក្សា នៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋអារ៉ាប់អេហ្ស៊ីប ចូលប្រទេស ដោយចប់អាណត្តិបេសកកម្ម។

- តែងតាំងលោក **ឆូង សុធីរា** បច្ចុប្បន្នអនុប្រធាននាយកដ្ឋានអង្គការអន្តរជាតិ ជាទីប្រឹក្សា នៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋអារ៉ាប់អេហ្ស៊ីប ជំនួសវិញ។

៨-ផ្លាស់កញ្ញា **ជា សុម៉ាលី** ទីប្រឹក្សា នៃស្ថានបេសកកម្មអចិន្ត្រៃយ៍កម្ពុជា ប្រចាំអង្គការសហប្រជាជាតិ នៅទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក ចូលប្រទេស ដោយចប់អាណត្តិបេសកកម្ម។

-តែងតាំងលោក **នេត សុវណ្ណារ៉ា** បច្ចុប្បន្នប្រធាននាយកដ្ឋានស្រាវជ្រាវ និងវិភាគយុទ្ធសាស្ត្រ ជាទីប្រឹក្សា នៃស្ថានបេសកកម្មអចិន្ត្រៃយ៍កម្ពុជា ប្រចាំអង្គការសហប្រជាជាតិ នៅទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក ជំនួសវិញ។

៩-តែងតាំងលោក **ទូច សុវ៉ាណរ៉ា** បច្ចុប្បន្នប្រធាននាយកដ្ឋានវិភាគ និងព្យាករណ៍នយោបាយតំបន់ និងពិភពលោក ជាអគ្គទីប្រឹក្សា នៃស្ថានតំណាងអចិន្ត្រៃយ៍កម្ពុជា អមលេខាធិការដ្ឋានអាស៊ាន នៅហ្សាការតា ប្រទេសឥណ្ឌូនេស៊ី។

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១៣រោច ខែ បុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ